HONEYCOMB 3/2 (April 2002): 75–83



# An Unexpectedly Precious Gift

*Susan CALDWELL*

Little did I know how God had been preparing me for his birth. Little did we know what this child would mean to our family.

Joshua is our fourth and youngest child, born over ten years ago with a medical problem known as Down syndrome. This condition affects him both physically and mentally. Shortly after Joshua's birth a doctor told us, "Your son will learn to do many of the things other children do ... but it will take him *longer*." It took him much longer than most children to learn to roll over, sit up, stand up, and walk. But eventually he did. Those were days of great rejoicing in our home!

Though now ten years old, Joshua looks and acts like a six-year-old and is in first grade. He is learning to read, write, and do arithmetic, but will never learn as quickly or as much as the average child.

Our story about Joshua began two years before he was born when I was pregnant with his brother, Caleb. In my home country, people commonly ask a pregnant woman, "What do you want—a boy or a girl?" A typical reply is, "I don't care, just as long as the baby is healthy." But I have never been able to say those words. First of all, I have a brother who has never been able to walk. Second, I knew that the God who made us and loves us has not *promised* that each child he

gives will be problem-free, either physically, mentally, emotionally, or spiritually.

Early in my pregnancy with Caleb, a blood test suggested I might be carrying a child with Down syndrome. For the next six months I fought with God in my heart. Like everyone else, I *wanted* a normal child, *not* one with Down syndrome. Only a few days before Caleb's birth did I experience a change of heart. While walking along the ocean near our home, the thought suddenly came to me, "If this child has some kind of problem, he *needs* me." My thoughts had turned from what *I* wanted to the needs of our child, and acceptance washed over my heart like the ocean waves sweeping over the sand before me. The fight was over. God won, and great was my joy. Not long after, Caleb was born, perfectly healthy.

While pregnant with Joshua two years later I refused the special blood tests, wanting to enjoy the pregnancy. And I did. How unexpectedly came the news only minutes after his birth: "He has Down syndrome." I could see in my mind a book on a shelf, once read. Taking the book in my hands, as it were, I opened it to the chapter and lesson learned two years earlier: This baby *needs* me. Our Father in Heaven had prepared me for his coming.

The morning after Joshua's birth, my husband Darrell came into the hospital room with a story. Our oldest son Luke, then nine years old, had asked his father on the way to school, "Dad, if God were to say to you, 'Which would you rather have—a child like Joshua or a normal child?' What would you say?"

Darrell's response: "What would you say, Luke?"

"I would say to God," Luke replied, 'Whatever *you* want, that's what *I* want."

Do you know what those words were to me? They were *just* what I needed to hear. No, more than that—they were just what my response needed to be: "Whatever *you* want, that's what *I* want." Joshua, like every child, was a gift from God,[1] and God was enabling us to accept his gift.

---

[1]Ps 127:3–5.

Still, we had to endure a "season" of grief and disappointment. It was as if the child we had been hoping for had died—we needed time to grieve the loss of that child. It was kind of like going through a storm that lasted for a while. Eventually, the storm passed, the sky cleared, and the sun shone once again.

Accepting the circumstances that God brought into our lives did not occur in a single moment, but over a long period of time. Many times God used his word to answer some of the deep questions of our hearts and to teach us truths that have instructed and guided us about having a child with special needs.

We have learned that God *takes responsibility* for how Joshua was made. One day while reading the story of Moses at the burning bush, I was struck with God's words to him: "Who gave man his mouth? Who makes him deaf or mute? Who gives him sight or makes him blind? Is it not I, Yahweh?"

Can you believe it? God was unashamedly taking responsibility for children who are born blind, deaf, and mute! It seemed reasonable to draw from that passage the truth that God was also taking responsibility for the way Joshua was formed in my womb. I cannot understand this. I only know that God can *never* be accused of doing wrong,[2] and that his will for us is "good, pleasing, and perfect."[3]

We also believe that there is *purpose* in Joshua's life. One day I read a question Jesus' disciples asked him about a certain blind man: "Who sinned, this man or his parents, that he was born blind?"

His disciples believed, like the people of that day, that there was a direct relationship between the man's or his parents' sin and this man's blindness. Jesus' answer must have surprised them: "Neither this man nor his parents sinned, but this happened so that *the work of God might be displayed in his life.*"

What wonderful news for that man and his family! The man's blindness was not a punishment for wrongdoing; instead, it was an opportunity for the work of God to be seen in his life. Likewise, there

---

[2]Deut 32:4.

[3]Rom 12:2.

is purpose in Joshua's having physical and mental problems—"that the work of God might be displayed in his life."

One way we have seen the work of God displayed in his life is in his personality and character. For example, he freely expresses *praise* to God. Sometimes while riding along on a moto, in the car, or playing at home, Joshua sings unaware and not caring that others may be watching and listening, and not attempting to draw attention to himself (though like every child, he is quite capable of doing that, too!). One day while walking along a road he sang over and over again, in a loud voice, "Oh the blood of Jesus, oh the blood of Jesus, it washes white as snow." Now there is a message that needs to be heard! The psalmist says, "From the lips of infants and children you have ordained praise."[4]

Joshua has a simple but strong *trust* in Jesus. One day last summer we were climbing a long, steep set of wooden stairs in the country. Joshua was getting tired, but we still had a long way to go. He started saying over and over, "Come on, Jesus; come on, Jesus...." until finally we reached the top. And then he burst into a heart-felt, "Praise the Lord!"

Another way we see the work of God in his life is through his *compassion* for people. One day while playing alone in our yard, he noticed a boy leading a blind man down our dirt road. Joshua ran to our bedroom, grabbed a twenty-dollar bill from our desk drawer (without permission) and ran to the front gate calling after them, "Boy! Boy!" His heart was touched by their need.

He is also very *patient*—both with himself and with others. His speech is not so clear as the normal child, and sometimes I cannot understand what he is saying. I may ask him again and again to repeat it, or to explain to me using other words. Joshua never shows impatience with this process. He keeps at it until I understand. I wish I were more like he.

He is very *friendly, accepting, and loving.* While riding by motodope on a Phnom Penh street, Joshua may call out a friendly, "Hello!" to some stranger. People are *attracted* to one whom they

---

[4]Ps 8:2.

sense loves and accepts them. Yes, he feels and expresses anger like the rest of us, but he is also very quick to forgive. These are some of the gifts that Joshua brings to the human family. And these are some of the ways in which, as different as he is from what we think of as normal, "the work of God [is displayed] in his life."

Over the years, on many occasions, God has shown his protection over this child who does not understand danger as well as other children. We have always had to be very careful about making sure that our home (and wherever else he may be) is a safe place for him.

In 1997 he found his way to the peak of a villa roof in Phnom Penh. Thankfully, he was discovered by another child and rescued, unhurt, by our oldest son. The message God communicated to my heart after that frightening experience was: "I am watching over Joshua." Is this not also "the work of God displayed in his life"?

In 1999 we were visiting our home country. I remember speaking in a church one Sunday in July about how God had proven his protection of our family. I went on to say with deep conviction, "And even if one of us were to be hurt or killed, *he is still God and we will still trust him.*"

That very afternoon about twenty of us were walking up and down the streets of that city, searching for Joshua. He had wandered away during a backyard picnic. The name of the city is Lynn, and a local proverb warns, "Lynn, Lynn, the city of sin. You don't come out the way you went in." As we searched I remembered what I had so boldly asserted in church that morning, and cried out to God, "Are you going to make me live out those words this very day?"

Thank God, he did not. After what seemed like an eternity, Joshua turned up at the police station. Someone had seen this little boy about to cross a busy street, took his hand, and led him to a safe place ... where his father found him and brought him back to his family.

When my husband came home with Joshua and I took him in my arms, I could not help but cry tears of utter relief. Joshua put his little arms around me and said a tender and heartfelt, "Sorry, Mom." We give glory to God who displays his work in the life of a child whose ability to understand is not as great as most children.

Quite honestly, Joshua's lowered mental ability has been the most difficult thing for me to accept. As I have considered the reason for this over the years, I believe it has to do with society's silent (though loud and clear) message that the mentally retarded are less valuable.

I needed the truths of God's word to battle this lie. Both the creation story in Genesis and the story of salvation throughout the Bible paint a clear picture: Human beings have far greater worth than anything else God has created. Only human beings were made in God's image and have the unique potential to have a relationship with their Creator. It was love for *people* that motivated God to send his son to die for *people*. People have value simply because their Creator has made it so.

Consider all the times Jesus spent healing people with needs in their bodies, minds, and spirits. He obviously did not consider them less valuable. He stopped, he noticed, he took the time to care for them. The message? People mattered to Jesus. And people with needs touched his heart.

Children also touched his heart. Although his disciples considered Jesus' time far too valuable to squander on little ones, Jesus made it perfectly clear that to him they mattered a great deal. "Let the children come to me, and do not hinder them, for the kingdom of God belongs to such as these."[5]

Joshua happens to be a child who is mentally retarded. But that is not a description of his worth. It just means his potential to learn is not as great as that of most children. However, he *can* learn and, in fact, has gone to school since he was three years old. He has always been in classes with "normal" children. This gives him the much-needed opportunity to be with other children, and gives his classmates the opportunity to relate to a person who is different from them. Of course, going to school also means that his teachers have to adjust their classroom goals and methods to fit Joshua's abilities. But Joshua's teachers have always been eager to do all they can to help him meet his potential. And that is what we see as the most important goal in formally educating him.

---

[5]Matt 19:14.

One of the most important aspects of educating Joshua is helping him learn good behavior. It perhaps takes more patience, persistence, and consistent effort to teach a child such as he how to conduct himself. But I have seen over the years that he can learn good behavior, and he has made much progress in this area. I am very grateful to all of his teachers who have exerted such a positive influence in this area of his life, and have helped us to expect a higher level of good behavior from him.

I remember when Joshua first went to school in Phnom Penh his teacher asked, "What do you do to help Joshua obey?" Thankfully, by that time I had learned that there was one thing Joshua disliked almost more than anything else, and that was a "consequence." Even at his young age he understood well its meaning: Something he would *not* want to experience.

A "consequence" might be having to sit alone for a while, not being allowed to play with a friend or his favorite toys, losing some special sweet cookie or cake after a meal, or not being able to watch television. The most important thing about a "consequence" is that it has to be something he would *not* want to endure. These particular "consequences" are meaningful for Joshua because he is a boy who loves being with people, playing with friends, playing with toys, eating sweets, and watching television.

An effective "consequence" not only has to be an undesired event, but it has to occur soon after the unacceptable behavior. For example, if Joshua is misbehaving *now*, the "consequence" must occur as soon as possible so that he understands the connection between his undesired behavior and the "consequence."

Whenever I say the words, "Joshua, do you want a consequence?" I better have one in mind in case his behavior does not improve. When I first started using this method of correction, I often had to impose a "consequence." It was as if Joshua were saying, "I don't really believe you will do anything that I don't like." Now he believes me and rarely tests me when I ask him the question.

However, he does have a stubborn streak. Occasionally, he acts like a cow that stands still and refuses to budge no matter how hard one tries to move it. In fact, the more one prods the cow, the

more firmly it resists! At such times, the best thing for Joshua is to be alone until his stubborn streak quiets down within him.

Finally, I must be careful not to overuse the "consequence" method. Like cloth that will wear out from constant use, this method of correcting his behavior will no longer be useful if I ask the question too frequently.

Sometimes I have to think about *why* Joshua's behavior is not appropriate on a given occasion. Recently his teacher called me from school at lunchtime. "Joshua and another boy were in the changing room after swimming," she said. "We heard Joshua screaming and ran inside. They had been hitting each other." We never learned from Joshua why he was so angry with the other boy. Joshua only said, "He hit me."

When his doctor heard this story several days later she asked, "Was the other boy a new student?"

Surprised, I replied, "Yes. How did you know?"

"Of course he was a new student," was all she said.

His teacher told me, "When Joshua is saying or doing something the other children know is naughty, his friends who know him well say, 'Don't pay any attention to him.' They understand at their young age that he just wants their attention, so they are making a very wise decision: Ignore him!"

When Joshua has a sudden, unusually strong outburst of improper behavior, I have learned to ask myself, "Is he getting sick?" I have observed this enough times to keep this question in the back of my mind. Of course, Joshua is also capable of becoming angry with another child just like all children. We try to understand the cause of the outburst. In the case of the changing room story, I learned a few days later that he had an ear infection and was, indeed, sick. That may have been the cause of his outburst of anger. And then again, maybe not. Sometimes we just don't know.

We simply do not have all the answers about how to raise this child ... or any of our children for that matter. We pray for God to give us wisdom. He loves to answer that request.[6]

---

[6]Jas 1:5.

We do not know Joshua's potential. God does. He knows his plans for our son.[7] We are filled with hope, not because of what he may accomplish in the eyes of men, but because we believe the words of Jesus: "This happened that the work of God might be displayed in his life."[8]

Now when I think of how I fought with God over receiving a child like Joshua ... well, I smile. He has turned out to be an unexpectedly precious gift. "As for God, His way is perfect."[9] To God be the glory!



---

[7]Jer 29:11.

[8]Jn 9:3.

[9]Ps 18:30.

សំណុំនិក្ខុំ ៣/២ (មេសា ២០០២)ៈ ៨៤-៩៩



# អំណោយទានដ៏មានតម្លៃ ដែលមិនបានគិតទុកជាមុន

*អ្នកស្រី ស៊ូសាន ខដវែល*

ខ្ញុំបានដឹងតិចតួចណាស់ថាព្រះជាម្ចាស់បានរៀបចំសំរាប់ឲ្យខ្ញុំត្រៀមទទួលនូវកំណើតរបស់កូននោះ ។ ខ្ញុំបានដឹងតិចតួចណាស់ថា តើកូននោះមានអត្ថន័យបែបណាចំពោះគ្រួសារយើង ។

*យ៉ូស្វេ* ជាកូនទីបួន និងជាកូនពៅរបស់យើងដែលបានកើតមកកាលពីជាង១០ឆ្នាំមុន ដោយមានបញ្ហាមួយដែលផ្នែកវេជ្ជសាស្ត្រគេឲ្យឈ្មោះថា Down syndrome (ភាពយឺតយ៉ាវខុសប្រក្រតី) ។ លក្ខណៈមិនប្រក្រតីនេះមានឥទ្ធិពលប៉ះពាល់ដល់កូននោះ ទាំងផ្នែករូបកាយ និងផ្នែកសតិបញ្ញា ។ មិនយូរប៉ុន្មានក្រោយមក វេជ្ជបណ្ឌិតបានប្រាប់យើងថា "កូនរបស់អ្នកនឹងរៀនធ្វើការជាច្រើន ដែលក្មេងដទៃទៀតត្រូវរៀននោះ... ប៉ុន្តែកូននេះនឹងត្រូវចំណាយពេលយូរទើបរៀនធ្វើការទាំងនោះបាន" ។ គឺវាត្រូវចំណាយពេលយូរជាងក្មេងដទៃជាច្រើនទៀត ដើម្បីរៀនក្រឡាប់ អង្គុយ ឈរ និងរៀនដើរ។ ប៉ុន្តែក្រោយមកវាបានមានឆ្លងកាត់ដំណាក់ការទាំងនោះរួច ។ យើងក៏មានថ្ងៃដ៏សប្បាយរីករាយបំផុតនៅក្នុងផ្ទះរបស់យើង!

មកដល់ឥឡូវនេះវាមានអាយុ១០ឆ្នាំហើយ *យ៉ូស្វេ* មើលទៅការប្រព្រឹត្តិរបស់វាហាក់បីដូចជាកូនក្មេងដែលមានអាយុ៦ឆ្នាំ និងដូចជាក្មេងដែលរៀននៅថ្នាក់ទីមួយ ។ វារៀនអាន សរសេរ និងធ្វើគណិតសាស្ត្រ ប៉ុន្តែវារៀនមិនលឿន ឬមិនបានច្រើនដូចក្មេងដទៃទៀយ ។

រឿងរបស់យើងស្តីអំពី*យ៉ូស្វេ*ចាប់ផ្តើមឡើងកាលពី ២ឆ្នាំ មុនពេលដែល*យ៉ូស្វេ*កើតមកនោះ គឺនៅពេលដែលបងរបស់វាឈ្មោះ *កាលែប* នៅក្នុងពោះ ។ នៅក្នុងប្រទេសរបស់ខ្ញុំ តាមធម្មតាគេតែងសួរដល់ស្ត្រីមានផ្ទៃពោះថា "តើអ្នកចង់បានកូនប្រុសឬកូនស្រី?" ចម្លើយដែលជាទូទៅ នោះគឺថា "ខ្ញុំមិនខ្វល់ទ្បើយ ឲ្យតែកូននោះមានសុខភាពល្អបានហើយ" ។ ប៉ុន្តែខ្ញុំមិនអាចនិយាយពាក្យទាំងឡាយនោះបានឡើយ ។ ដំបូងបង្អស់នោះ ខ្ញុំមានប្អូនប្រុសម្នាក់ដែលពិការមិនអាចដើរបានឡើយ ។ ទីពីរ ខ្ញុំបានដឹងថាព្រះជាម្ចាស់ដែលព្រះអង្គបង្កើតយើងមក និងស្រឡាញ់យើងនោះ មិនដែលសន្យាថា គ្រប់ក្មេងដែលព្រះអង្គបង្កើតមកនោះ សុទ្ធតែគ្មានបញ្ហានោះឡើយ គឺមានន័យថា អាចមានបញ្ហាផ្នែករូបកាយ ផ្នែកសតិបញ្ញា ផ្នែកផ្លូវចិត្ត ឬផ្នែកខាងវិញ្ញាណ ។

នៅពេលដែលខ្ញុំមានផ្ទៃពោះកូនខ្ញុំឈ្មោះ *កាលែប* ប៉ុន្មានខែដំបូងការពិនិត្យឈាមបានបង្ហាញថា ខ្ញុំអាចកំពុងតែមានកូនដែលមានលក្ខណៈមិនប្រក្រតី ។ នៅក្នុងរយៈពេល៦ខែបន្ទាប់ពីពេលនោះមក ខ្ញុំបានឈ្លោះជាមួយព្រះជាម្ចាស់នៅក្នុងចិត្តរបស់ខ្ញុំ ។ ខ្ញុំក៏ដូចជាមនុស្សគ្រប់រូបដទៃទៀតដែរ ខ្ញុំចង់បានកូនដែលគ្រប់លក្ខណៈធម្មតា មិនមែនចង់បានកូនដែលមានលក្ខណៈមិនប្រក្រតីនោះឡើយ ។ ប៉ុន្មានថ្ងៃមុនថ្ងៃដែលត្រូវប្រសូតកូនរបស់ខ្ញុំឈ្មោះកាលែប ខ្ញុំមានអារម្មណ៍នៅក្នុងខ្លួនថាខ្ញុំមានការផ្លាស់ប្តូរនៅក្នុងចិត្ត ។ នៅក្នុងខណៈពេលដែលខ្ញុំកំពុងតែដើរនៅតាមបណ្តោយឆ្នេរសមុទ្រនៅជិតផ្ទះរបស់យើង រំពេចនោះគំនិតមួយផុសនៅក្នុងចិត្តរបស់ខ្ញុំ "បើកូននេះមានបញ្ហាខ្លះៗនោះ គឺកូននេះត្រូវការខ្ញុំ" ។ គំនិតខ្ញុំប្តូរពីអ្វីដែលខ្ញុំចង់បានទៅជា

សេចក្តីត្រូវការរបស់កូនយើងទៅវិញ ហើយការព្រមទទួលគំនិតនោះបាន លាងចិត្តរបស់ខ្ញុំប្រៀបដូចជារលកសមុទ្រដែលកំពុងបក់បោកលាងឆ្នេរខ្សាច់នៅចំពោះមុខខ្ញុំដែរ ។ ការមានអារម្មណ៍ច្របូកច្របល់នៅក្នុងចិត្តរបស់ខ្ញុំបានកន្លងផុតទៅ ។ ព្រះជាម្ចាស់ទទួលជ័យជម្នះ ហើយការអស្ចារ្យនោះគឺជាក្តីអំណររបស់ខ្ញុំ ។ មិនយូរប៉ុន្មានបន្ទាប់ពី *កាលែប* កើតមកនោះយើងឃើញថាកូននោះមានសុខភាពល្អបំផុត ។

លុះដល់ពីរឆ្នាំក្រោយមកនៅពេលដែលខ្ញុំមានទម្ងន់ *យ៉ូស្វេ* ខ្ញុំបដិសេធមិនព្រមទៅធ្វើពិសោធឈាមដើម្បីពិនិត្យថា តើកូននៅក្នុងផ្ទៃមានលក្ខណៈបែបណា ព្រោះខ្ញុំចង់បាននូវអារម្មណ៍ស្ងប់សុខនៅពេលដែលខ្ញុំមានផ្ទៃពោះ ។ ខ្ញុំក៏សម្រេចធ្វើបែបនោះមែន ។ តែប៉ុន្មាននាទីក្រោយពីកូននោះកើតមកមានដំណឹងមួយដែលស្មានមិនដល់បានឮមកដល់ខ្ញុំថា៖ "កូននោះមានបញ្ហាគឺមានលក្ខណៈយឺតយ៉ាវខុសប្រក្រតី" ។ ខ្ញុំអាចស្រមៃនឹកឃើញនៅក្នុងគំនិតរបស់ខ្ញុំនូវសៀវភៅមួយក្បាលនៅលើធ្នើរ ដែលខ្ញុំធ្លាប់អានម្តងរួចមកហើយនោះ ។ ខ្ញុំបានយកសៀវភៅមកកាន់ជាប់នៅនឹងដៃរបស់ខ្ញុំដូចដែលខ្ញុំធ្លាប់កាន់នៅដៃពីមុន ខ្ញុំបានបើកទៅជំពូក និងមេរៀនដែលខ្ញុំបានរៀនកាលពី២ឆ្នាំមុនដែលមានន័យថា៖ ទារកតូចនេះត្រូវការខ្ញុំ ។ ព្រះបិតារបស់យើងដែលគង់នៅឯស្ថានសួគ៌ព្រះអង្គបានរៀបចំឲ្យខ្ញុំទទួលយកការពិតនេះ ។

នៅពេលព្រឹកបន្ទាប់ពី *យ៉ូស្វេ* កើតមកនោះ *ដារ៉ែល* ជាប្តីរបស់ខ្ញុំបានមកក្នុងបន្ទប់នៅមន្ទីរពេទ្យដោយយករឿងមកនិយាយប្រាប់ខ្ញុំ ។ កូនប្រុសច្បងរបស់យើង ឈ្មោះ *លូកា* មានអាយុទើបតែ៩ឆ្នាំ នៅតាមផ្លូវទៅសាលារៀនវាបានសួរទៅឪពុករបស់គេថា "ប៉ា បើព្រះជាម្ចាស់មានបន្ទូលមកប៉ាថា៖ តើកូនមួយណាដែលឯងចង់បាន គឺកូនដូចជា *យ៉ូស្វេ* ឬជាកូនដែលមានលក្ខណៈធម្មតា? តើប៉ានិយាយយ៉ាងម៉េចទៅ?"

*ដារ៉ែល* ឆ្លើយទៅ *លូកា* ថា៖ "តើកូននឹងឆ្លើយទៅព្រះវិញដូចម្ដេចទៅ *លូកា?*"

*លូកា* ឆ្លើយថា៖ "ខ្ញុំនឹងនិយាយទៅព្រះជាម្ចាស់វិញថា អ្វីក៏ដោយឲ្យតែព្រះអង្គសព្វព្រះហឫទ័យ នោះទូលបង្គំក៏នឹងចង់បានតាមនោះដែរ?" ។

តើលោកអ្នកដឹងទេថា ពាក្យទាំងនោះហើយដែលជាពាក្យសំរាប់ខ្ញុំ? ពាក្យទាំងនោះ គឺជាអ្វីដែលខ្ញុំជាត្រូវការពួ ។ ខ្ញុំមិនត្រូវការអ្វីលើសពីនោះឡើយ ។ ពាក្យនោះគឺជាអ្វីដែលខ្ញុំត្រូវការនៅក្នុងការឆ្លើយតបរបស់ខ្ញុំគឺ៖ "អ្វីក៏ដោយឲ្យតែព្រះអង្គសព្វព្រះហឫទ័យ នោះហើយជាអ្វីដែលខ្ញុំម្ចាស់ត្រូវការ"។ *យ៉ូស្វេ* ដូចជាក្មេងទូទៅដែរ គឺគេជាអំណោយទានមកពីព្រះជាម្ចាស់[១] ហើយព្រះជាម្ចាស់ផ្ដល់ឲ្យយើងអាចទទួលយកអំណោយទានរបស់ព្រះអង្គបាន ។

យើងនៅតែត្រូវទទួលរងនូវការ"រងទុក្ខព្រួយ" និងការខកចិត្តយូរៗម្ដងដែរ ។ គឺវាហាក់បីដូចជាកូនដែលយើងសង្ឃឹមចង់បាននោះ បានស្លាប់បាត់ទៅហើយ គឺបានសេចក្ដីថាយើងត្រូវការពេលវេលាដើម្បីសោកសង្រេងចំពោះការបាត់បង់កូននោះ ។ ចំពោះការនោះគឺវាហាក់បីដូចជាយើងកំពុងឆ្លងកាត់ព្យុះបក់បោកយ៉ាងខ្លាំងអស់រយៈពេលមួយស្របក់ ។ ទីបំផុត ព្យុះកំណាចនោះក៏បានកន្លងផុតទៅ ផ្ទៃមេឃក៏ស្រឡះ ហើយព្រះអាទិត្យក៏ជះរស្មីឡើងវិញម្ដងទៀត ។

ការព្រមទទួលយកកាលៈទេសៈទាំងឡាយ ដែលព្រះជាម្ចាស់បាននាំមកនៅក្នុងជីវិតរបស់យើងនោះ មិនមែនកើតឡើងទៅបានតែក្នុងមួយពេលព្រមគ្នានោះឡើយ ប៉ុន្តែត្រូវចំណាយពេលយ៉ាងយូរទើបយើងអាចទទួលយកបាន ។ ព្រះជាម្ចាស់ប្រើព្រះបន្ទូលរបស់ព្រះអង្គជាច្រើនដង ដើម្បីឆ្លើយទៅនឹងសំណួរទាំងឡាយដែលកប់ជ្រៅនៅក្នុងដួងចិត្តរបស់យើង ហើយដើម្បី

---

[១] *ទំនុក.១២៧:៣-៥*

បង្រៀនយើងនូវសេចក្តីពិតដែលបង្ហាត់យើង និងដឹកនាំឲ្យយើងដឹងពីការមានកូនដែលត្រូវការយើងជាពិសេស ។

យើងត្រូវរៀនឲ្យដឹងថា ព្រះជាម្ចាស់ទទួលខុសត្រូវចំពោះការដែលព្រះអង្គបង្កើត*យ៉ូស្វេ*មកនោះ ។ នៅថ្ងៃមួយ ពេលដែលខ្ញុំអានរឿងរបស់*ម៉ូសេ* នៅពេលដែលគាត់ទៅមើលភ្លើងឆេះគុម្ពបន្លា ខ្ញុំមានចិត្តរំភើបយ៉ាងខ្លាំងចំពោះព្រះបន្ទូលដែលព្រះអង្គមានបន្ទូលទៅកាន់គាត់ថា៖ "តើនរណាផ្តល់មាត់មកឲ្យមនុស្ស? តើនរណាធ្វើឲ្យមនុស្សថ្លង់ ឬគបាន? តើនរណាធ្វើឲ្យមនុស្សអាចមើលឃើញ ឬខ្វាក់បាន? តើមិនមែនអញជាព្រះយេហូវ៉ា ទេឬ?"

តើលោកអ្នកជឿការនេះទេ? ព្រះជាម្ចាស់មិនមានភាពអាម៉ាស់ចំពោះការទទួលខុសត្រូវដល់ក្មេងដែលបានកើតមកហើយខ្វាក់ភ្នែក ថ្លង់ និងមិនអាចនិយាយបាននោះឡើយ! គឺជាការសមហេតុសមផលដែរ ចំពោះការដកស្រង់យកសេចក្តីពិតដែលថា ព្រះជាម្ចាស់ក៏ទទួលខុសត្រូវចំពោះការដែល*យ៉ូស្វេ*ត្រូវកើតមកដោយរបៀបណានៅក្នុងផ្ទៃរបស់ខ្ញុំនោះ ។ ខ្ញុំមិនអាចយល់បានសោះចំពោះរឿងនេះ ។ ខ្ញុំគ្រាន់តែអាចដឹងថា យើងមិនអាចចោទប្រកាន់ចំពោះព្រះជាម្ចាស់ថាព្រះអង្គបានធ្វើខុសនោះឡើយ[២]ហើយដោយព្រោះថាបំណងព្រះរាជហឫទ័យរបស់ព្រះអង្គសំរាប់យើងនោះគឺ "ល្អគាប់ចិត្ត និងគ្រប់លក្ខណ៍"[៣] ។

យើងក៏ជឿផងដែរថា ព្រះជាម្ចាស់មានគោលដៅនៅក្នុងជីវិតរបស់*យ៉ូស្វេ* ។ នៅថ្ងៃមួយ ខ្ញុំបានអានសំណួរដែលសិស្សរបស់ព្រះយេស៊ូបានទូលសួរទៅព្រះអង្គស្តីពីមនុស្សពិការភ្នែក គេសួរថា៖ "តើនរណាជាអ្នកធ្វើបាប តើមនុស្សនេះ ឬឪពុកម្តាយរបស់គាត់ បានជាគាត់កើតមកខ្វាក់ភ្នែកដូច្នេះ?"

---

[២] *ចោទិ. ៣២:៤*

[៣] *រ៉ូម ១២:២*

សិស្សរបស់ព្រះយេស៊ូក៏ដូចមនុស្សជាច្រើននៅសម័យនោះដែរ គេជឿថាការពិការភ្នែកនោះ គឺមានការទាក់ទងទៅនឹងអំពើបាបផ្ទាល់របស់មនុស្សនោះ ឬអំពើបាបរបស់ឪពុកម្តាយ ។ ចម្លើយរបស់ព្រះយេស៊ូបានធ្វើឲ្យគេចម្លែកក្នុងចិត្តយ៉ាងខ្លាំងនោះគឺថា៖ "មិនមែនជាអំពើបាបរបស់មនុស្សនោះ ឬអំពើបាបរបស់ឪពុកម្តាយរបស់គាត់នោះឡើយ ប៉ុន្តែការនេះកើតឡើង ដើម្បីឲ្យការងាររបស់ព្រះជាម្ចាស់ អាចបង្ហាញឲ្យគេឃើញនៅក្នុងជីវិតរបស់មនុស្សនោះ" ។

នេះជាដំណឹងដ៏ល្អអស្ចារ្យសំរាប់គាត់ និងគ្រួសាររបស់គាត់! ការដែលគាត់ពិការភ្នែកនោះ មិនមែនជាការដាក់ទោសចំពោះកំហុសអ្វីមួយដែលគាត់ធ្វើខុសនោះឡើយ តែផ្ទុយទៅវិញ ការនេះកើតឡើងដើម្បីឲ្យការងាររបស់ព្រះជាម្ចាស់បានបង្ហាញឲ្យគេឃើញនៅក្នុងជីវិតរបស់គាត់ទៅវិញទេ ។ ដូចគ្នានេះដែរ ចំពោះការដែលយ៉ូស្វេមានបញ្ហាផ្នែករាងកាយ និងផ្នែកសតិបញ្ញានោះ គឺព្រះជាម្ចាស់មានផែនការថា "ដើម្បីឲ្យការងាររបស់ព្រះជាម្ចាស់អាចបង្ហាញឲ្យគេឃើញនៅក្នុងជីវិតរបស់វា" ។

មានរបៀបមួយដែលយើងឃើញថា ការងាររបស់ព្រះជាម្ចាស់បង្ហាញឲ្យឃើញនៅក្នុងជីវិតរបស់វានោះ គឺនៅក្នុងបុគ្គលិកលក្ខណៈ និងចរិករបស់វា ។ ឧទាហរណ៍ វាបង្ហាញពីការដែលវាសរសើរតម្កើងដល់ព្រះជាម្ចាស់នោះគឺផុសឡើងឯងពីចិត្តរបស់វា មិនបាច់មាននរណាប្រាប់វាឡើយ ។ ជួនកាលនៅពេលកំពុងជិះម៉ូតូ ឬនៅក្នុងឡាន ឬពេលលេងនៅក្នុងផ្ទះ *យ៉ូស្វេ* ច្រៀងដោយមិនខ្វល់ថាមានអ្នកណាស្តាប់ និងអ្នកណាមើលវាឡើយ និងវាមិនព្យាយាមឲ្យគេចាប់អារម្មណ៍យកចិត្តទុកដាក់នឹងវាឡើយ (ទោះជាយ៉ាងណាក៏ដោយ វាក៏ដូចជាក្មេងគ្រប់រូបដែរ វាអាចមានសមត្ថភាពគ្រប់គ្រាន់សំរាប់ធ្វើការនោះផងដែរ!) ។ នៅថ្ងៃមួយ នៅក្នុងខណៈពេលកំពុងដើរនៅតាមបណ្តោយផ្លូវ វាស្រែកច្រៀងខ្លាំងៗ ច្រៀងហើយច្រៀងទៀតថា៖ "អូព្រះ

លោហិតរបស់ព្រះយេស៊ូ អូព្រះលោហិតរបស់ព្រះយេស៊ូ លាងសំអាតឲ្យបានសស្គុះដូចជាហិមៈ" ។ ឥឡូវនេះមានព្រះរាជសារមួយដែលយើងគួរតែឮ! អ្នកនិពន្ធទំនុកតម្កើងនិយាយថា៖ "ព្រះអង្គបានប្រើពាក្យសរសើរតម្កើងរបស់ក្មេងៗ និងទារកដែលនៅបៅដោះ" [៤]

*យ៉ូស្វេ* មានលក្ខណៈសាមញ្ញ ប៉ុន្តែរឹងប៉ឹងក្នុងការទុកចិត្តដល់ព្រះយេស៊ូ ។ ថ្ងៃមួយកាលពីរដូវប្រាំងឆ្នាំទៅមិញ យើងឡើងជណ្តើរឈើមួយចោតហើយខ្ពស់ ពេលដែលយើងចេញទៅលេងនៅជនបទ ។ *យ៉ូស្វេ* អស់កម្លាំងខ្លាំងមែនទែន ប៉ុន្តែយើងត្រូវឡើងបន្តទៅឆ្ងាយទៀត ។ វាចាប់ផ្តើមនិយាយម្តងហើយម្តងទៀតថា៖ "ព្រះយេស៊ូ! ព្រះយេស៊ូ! សូមយាងមកជួយផង..." រហូតដល់ទីបំផុតយើងក៏បានឡើងទៅដល់ទីដៅនៅខាងលើផុត ។ ពេលនោះវាចាប់ផ្តើម "សរសើរព្រះអង្គ!" យ៉ាងអស់ពីចិត្ត ។

យើងបានឃើញការងាររបស់ព្រះជាម្ចាស់មួយបែបទៀតនៅក្នុងជីវិតរបស់វា គឺការមានចិត្តអាណិតអាសូរចំពោះមនុស្សដទៃ ។ ថ្ងៃមួយនៅពេលដែលយើងកំពុងអធិស្ឋាននៅក្នុងទីធ្លាខាងមុខផ្ទះរបស់យើង វាបានឃើញក្មេងប្រុសដើរដឹកដៃមនុស្សពិការភ្នែកម្នាក់កាត់តាមមុខផ្ទះរបស់យើង។ *យ៉ូស្វេ* បានរត់យ៉ាងលឿនទៅបន្ទប់ដេករបស់យើង យកលុយក្រដាស$២០ ពីក្នុងថតតុមក (ដោយមិនបានសុំការអនុញ្ញាតឡើយ) ហើយរត់តាមពីក្រោយក្មេងប្រុសនោះដោយស្រែកហៅឲ្យក្មេងប្រុសនោះមកយកលុយ ។ ដោយឃើញគេមានការខ្វះខាតនោះ ដួងចិត្តរបស់វាមានការរំជួលយ៉ាងខ្លាំង ។

*យ៉ូស្វេ* ក៏ជាមនុស្សមានការអត់ធ្មត់ណាស់ដែរ មិនថាចំពោះខ្លួនវាផ្ទាល់ និងជាមួយអ្នកដទៃឡើយ ។ សំដីរបស់វាមិនសូវច្បាស់ដូចក្មេងធម្មតាឡើយ ហើយជួនកាលខ្ញុំក៏មិនអាចយល់បាននូវអ្វីដែលវានិយាយដែរ ។ ខ្ញុំអាច

---

[៤] *ទំនុក.* ៨:២

សួរវាម្តងហើយម្តងទៀតដើម្បីឲ្យវានិយាយឡើងវិញ ឬដើម្បីឲ្យវាពន្យល់ខ្ញុំដោយប្រើពាក្យផ្សេងទៀត ។ *យ៉ូស្វេ* មិនដែលបង្ហាញការមួម៉ៅចំពោះការដែលខ្ញុំសួរបែបនេះឡើយ ។ វាព្យាយាមពន្យល់ខ្ញុំរហូតដល់ខ្ញុំអាចយល់បាន។ ខ្ញុំប្រាថ្នាចង់បានការអត់ធ្មត់ឲ្យបានដូចយ៉ូស្វេដែរ ។

*យ៉ូស្វេ* ជាមនុស្សរួសរាយរាក់ទាក់ ទទួលយកបាននូវអ្វីគ្រប់យ៉ាង និងគួរជាទីស្រឡាញ់ ។ នៅពេលដែលកំពុងជិះម៉ូតូឌុបនៅតាមផ្លូវនៅក្នុងទីក្រុងភ្នំពេញ *យ៉ូស្វេ* ស្រែកហៅអ្នកដែលធ្វើដំណើរទៅមកដោយសម្តែងនូវការរាក់ទាក់ជាមួយគេ ។ មនុស្សតែងតែសម្តែងនូវការរាក់ទាក់ចំពោះមនុស្សណាម្នាក់ដែលគេស្រឡាញ់ និងព្រមទទួលស្គាល់អ្នកនោះ ។ មែនវាមានអារម្មណ៍ និងសម្តែងចេញនូវកំហឹងរបស់វាចំពោះយើងរាល់គ្នា ប៉ុន្តែវាក៏ឆាប់អត់ទោសឲ្យគេដែរ ។ មានអំណោយទានខ្លះៗ ដែល*យ៉ូស្វេ*នាំយកមកជាមួយ ។ ទាំងនេះហើយដែលយើងគិតថា វាមានការខុសប្លែកពីធម្មតា តែយើងគិតថា វាធម្មតាទៅវិញទេដោយព្រោះថា "ការងាររបស់ព្រះជាម្ចាស់ត្រូវបានបង្ហាញឲ្យឃើញនៅក្នុងជីវិតរបស់*យ៉ូស្វេ*" ។

អស់រយៈពេលជាច្រើនឆ្នាំ ជាច្រើនលើកច្រើនគ្រា ព្រះជាម្ចាស់បានបង្ហាញនូវព្រះហឫទ័យការពារថែរក្សារបស់ព្រះអង្គចំពោះកូននេះដែលគ្មាមិនដែលដឹងមិនដែលយល់នូវអ្វីទៅដែលហៅថាការគ្រោះថ្នាក់ដូចជាក្មេងដទៃនោះឡើយ ។ យើងតែងតែមានការប្រុងប្រយត្ន័ជានិច្ច ទោះនៅផ្ទះ (ហើយនៅកន្លែងណាក៏ដោយ) យើងត្រូវដឹងប្រាកដថា មិនមានអ្វីដែលអាចបណ្តាយឲ្យគ្រោះថ្នាក់ដល់វានោះឡើយ ។

នៅក្នុងឆ្នាំ ១៩៩៧ វាបានឡើងទៅលើដំបូលផ្ទះយ៉ាងខ្ពស់មួយនៅក្នុងទីក្រុងភ្នំពេញ ។ អរគុណព្រះអង្គដែលមានក្មេងម្នាក់ទៀតមើលឃើញហើយកូនច្បងរបស់យើងជួយសង្គ្រោះវាឲ្យរួចពីគ្រោះថ្នាក់ ។ ព្រះរាជសារមួយដែលព្រះជាម្ចាស់មានបន្ទូលមកដួងចិត្តរបស់ខ្ញុំ បន្ទាប់ពីខ្ញុំមានការភ័យ

ខ្លាចយ៉ាងខ្លាំងចំពោះការនោះគឺ "អញជាអ្នកមើលថែ*យ៉ូស្វេ*"។ តើការនោះមិនមែនជាការងាររបស់ព្រះជាម្ចាស់ដែលបានសម្តែងចេញឲ្យឃើញនៅក្នុងជីវិតរបស់*យ៉ូស្វេ* ទេឬអី? "

នៅក្នុងឆ្នាំ ១៩៩៩ យើងបានទៅលេងស្រុកកំណើតរបស់យើង ។ ខ្ញុំនៅចាំបានថា នៅពេលថ្ងៃអាទិត្យមួយនៅក្នុងខែកក្កដាដែលខ្ញុំបានធ្វើបន្ទាល់នៅក្នុងព្រះវិហារមួយពីការដែលព្រះជាម្ចាស់ការពារថែរក្សាគ្រួសាររបស់យើង។ ខ្ញុំបាននិយាយបន្តទៅទៀតដោយដឹងច្បាស់នៅក្នុងចិត្តថា៖ "ទោះបើមាននរណាម្នាក់នៅក្នុងគ្រួសាររបស់យើងមានការឈឺចាប់ ឬក៏ស្លាប់ក៏ដោយ ព្រះអង្គនៅតែជាព្រះជាម្ចាស់ និងយើងនៅតែទុកចិត្តព្រះអង្គដដែល" ។

នៅពេលថ្ងៃរសៀលនោះឯង យើងមានគ្នាប្រហែល២០នាក់ នាំគ្នាដើរចុះ ដើរឡើងនៅតាមដងផ្លូវនៅក្នុងទីក្រុង ដើម្បីស្វែងរក*យ៉ូស្វេ* ។ វាបានដើរវង្វេងនៅពេលដែលយើងកំពុងទទួលទានអាហារនៅទីធ្លាខាងក្រោយផ្ទះ ។ ទីក្រុងនោះឈ្មោះថា ទីក្រុងលីន ដែលអ្នកនៅក្នុងទីក្រុងនោះបានលើកជាពាក្យស្លោកមួយឃ្លាថា៖ លីន លីន "ជាទីក្រុងនៃអំពើបាប" ។ គឺមានន័យថា អ្នកមិនអាចចេញមកវិញតាមផ្លូវដែលអ្នកចូលទៅនោះបានឡើយ" ។ នៅពេលដែលយើងកំពុងដើររកវានោះ ខ្ញុំនឹកចាំនូវអ្វីដែលខ្ញុំបានធ្វើបន្ទាល់នៅព្រះវិហារដោយក្លាហានកាលពីព្រឹកនោះ ហើយខ្ញុំបានស្រែកអំពាវនាវដល់ព្រះជាម្ចាស់ " ព្រះអង្គអើយ តើព្រះអង្គឲ្យខ្ញុំម្ចាស់បានដកពិសោធនូវពាក្យសំដីដែលខ្ញុំបាននិយាយកាលពីព្រឹកមិញនេះឯងឬ?"

អរគុណព្រះអង្គ *យ៉ូស្វេ* មិនបានស្លាប់ឡើយ ។ បន្ទាប់ពីដើររកអស់ចិត្តអស់ចង់ទៅនោះ គេក៏រក*យ៉ូស្វេ*ឃើញនៅប៉ុស្តិ៍នគរបាល ។ មានមនុស្សម្នាក់មើលឃើញក្មេងប្រុសនេះបំរុងដើរឆ្លងផ្លូវដែលចរាចរណ៍ចង្អៀតនោះ គេក៏ជួយដឹកដៃកូននោះដើរឆ្លងទៅរកកន្លែងដែលមានសុវត្ថិភាព ពេលនោះឪពុករបស់វាក៏បានរកឃើញវា ហើយនាំវាត្រឡប់មកផ្ទះជួបជុំគ្រួសារវិញ ។

នៅពេលដែលប្តីរបស់ខ្ញុំវិលត្រឡប់មកផ្ទះវិញ ជាមួយនឹងយ៉ូស្វេនោះ ខ្ញុំបានស្ទុះទៅអោបកូន ហើយខ្ញុំមិនអាចទប់ទឹកភ្នែកបានឡើយ ខ្ញុំក៏យំដោយបន្ធូរនូវភាពតានតឹងដែលខ្ញុំមានមុនពេលរកកូននោះឃើញ ។ *យ៉ូស្វេ* យកដៃតូចៗរបស់វាមកអោបខ្ញុំ ហើយនិយាយយ៉ាងស្រទន់ និងធ្វើឲ្យខ្ញុំរំជួលចិត្តថា "សុំទោសម៉ាក់" ។ យើងថ្វាយសិរីល្អដល់ព្រះជាម្ចាស់ដែលបានបង្ហាញការងាររបស់ព្រះអង្គនៅក្នុងជីវិតរបស់ក្មេងដែលមានការយល់ដឹងមិនដូចជាក្មេងដទៃនោះឡើយ ។

និយាយដោយស្មោះត្រង់ទៅ សតិបញ្ញាមិនឆ្លាតរបស់ *យ៉ូស្វេ* ជារឿងមួយពិបាកឲ្យខ្ញុំអាចទទួលយកបាន ។ នៅពេលដែលខ្ញុំពិចារណាហើយពិចារណាទៀតអស់រយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ ខ្ញុំជឿថាវាទាក់ទងទៅនឹងសម្លេងខ្សិបខ្សៀវរបស់សង្គម (មិនថាឡើយវាឮ និងច្បាស់លាស់ប៉ុណ្ណានោះទេ) ដែលថាការមានសតិបញ្ញាអន់ថយនោះមិនសូវមានតម្លៃនៅក្នុងសង្គមនោះឡើយ ។

ខ្ញុំត្រូវការសេចក្តីបំភ្លឺនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីតយុទ្ធជាមួយនិងសម្លេងភូតកុហកនេះ ។ រឿងនៃការកកើត និងរឿងនៃការសង្គ្រោះដែលមានចែងនៅក្នុងព្រះគម្ពីរលោកុប្បត្តិទាំងពីរនោះសុទ្ធតែបង្ហាញរូបភាពថា៖ មនុស្សជាតិ គឺមានតម្លៃពិសេសលើសលប់ជាងរបស់សព្វសារពើទាំងឡាយដទៃទៀតដែលព្រះជាម្ចាស់បានបង្កើតមក ។ មានតែមនុស្សទេដែលព្រះអង្គបង្កើតគេមកជារូបឆ្លុះរបស់ព្រះអង្គ ហើយមានសក្តានុពលដ៏សំខាន់ដាច់គេក្នុងការប្រាស្រ័យទាក់ទងជាមួយព្រះជាម្ចាស់ដែលជាព្រះអាទិករនោះ ។ ព្រះអង្គស្រឡាញ់មនុស្ស ទើបព្រះជាម្ចាស់ចាត់ព្រះរាជបុត្រារបស់ព្រះអង្គយាងមកសុគតជំនួសបាបរបស់មនុស្សលោកយើង ។ មនុស្សមានតម្លៃក៏ដោយសារតែព្រះអាទិករបង្កើតគេមកឲ្យមានតម្លៃបែបនោះឯង ។

ចូរពិចារណាមើលពីព្រះយេស៊ូ ព្រះអង្គចំណាយពេលប្រោសជម្ងឺដល់មនុស្សដែលឈឺទាំងរូបកាយ គំនិត និងវិញ្ញាណរបស់គេ ។ ព្រះអង្គមិនបានគិតថា គេគ្មានតម្លៃនោះឡើយ ។ ពេលព្រះអង្គកំពុងតែយាងកាត់ហ្វូងមនុស្ស ព្រះអង្គឈប់ ព្រះអង្គសង្កេតមើល ព្រះអង្គចំណាយពេលមើលថែគេ ។ ព្រោះហេតុអ្វីទៅ? ព្រះយេស៊ូរាប់មនុស្សថាជារឿងសំខាន់ ។ មនុស្សទាំងឡាយនោះធ្វើឲ្យព្រះអង្គរំជួលព្រះហឫទ័យ ។

ក្មេងៗក៏ធ្វើឲ្យព្រះអង្គរំជួលព្រះហឫទ័យដែរ ។ ថ្វីត្បិតតែសិស្សរបស់ព្រះយេស៊ូគិតថា ពេលវេលារបស់ព្រះអង្គមានតម្លៃបំផុត នោះទើបគេឃាត់ក្មេងៗមិនឲ្យទៅជិតព្រះយេស៊ូ ប៉ុន្តែព្រះយេស៊ូបានបញ្ជាក់យ៉ាងច្បាស់ថាចំពោះព្រះអង្គក្មេងៗសំខាន់ណាស់ ។ " ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវារាល់គ្នា ។ "[៥]

*យ៉ូស្វេ*បានកើតមកជាក្មេងមានបញ្ហាទន់ទាបផ្នែកសតិបញ្ញាមែន ។ តែមិនមែនបានសេចក្តីថា ការនោះពណ៌នាពីតម្លៃរបស់វាឡើយ ។ គឺវាគ្រាន់តែមានន័យថា សមត្ថភាពនៃការរៀនសូត្ររបស់វាមិនបានពូកែដូចជាក្មេងដទៃភាគច្រើនតែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក៏ដោយក៏វាអាចរៀនបានហើយតាមពិតទៅវាទៅចូលរៀននៅឯសាលាតាំងពីវាអាយុបីឆ្នាំម៉្លេះ ។ វាចូលរៀនជាមួយនឹងក្មេងៗ "ធម្មតា" ។ ការនេះបានផ្តល់ឱកាសឲ្យវាបានច្រើនដើម្បីបាននៅជាមួយក្មេងដទៃទៀត ហើយក៏ជាឱកាសផ្តល់ឲ្យសិស្សរួមថ្នាក់របស់វាអាចមានពេលទាក់ទងជាមួយក្មេងដែលមានលក្ខណៈមិនធម្មតាដូចជាពួកគេនោះ ។ តាមពិតទៅ ការដែលវាទៅរៀននៅឯសាលានោះ មានន័យថាគ្រូរបស់វាត្រូវតែកែសម្រួលពីទិសដៅរបស់ថ្នាក់រៀន និងវិធីសាស្ត្រនៃការបង្រៀនដើម្បីឲ្យស៊ីនឹងសមត្ថភាពរបស់*យ៉ូស្វេ* ។ ប៉ុន្តែគ្រូរបស់*យ៉ូស្វេ*តែងតែ

---

[៥] *ម៉ាថាយ ១៩:១៤*

ខំយកចិត្តទុកដាក់ធ្វើគ្រប់យ៉ាងទាំងអស់តាមដែលអាចធ្វើបាន ដើម្បីជួយឲ្យវាអាចរៀនបាន ។ នេះជាគោលដៅសំខាន់បំផុតដែលយើងឃើញនៅក្នុងការអប់រំវាតាមបែបជាផ្លូវការនោះ ។

ចំណុចសំខាន់ក្នុងការអប់រំយ៉ូស្វេនោះ គឺការជួយឲ្យវាមានអាកប្បកិរិយាល្អ ។ ការនេះត្រូវការនូវការអត់ធ្មត់បំផុតក្នុងការព្យាយាមហើយព្យាយាមទៀតដើម្បីបង្រៀនក្មេងបែបនេះឲ្យគេមានអាកប្បកិរិយាល្អនោះ ។ ប៉ុន្តែបើខ្ញុំសង្កេតមើលរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនោះ ខ្ញុំឃើញថាវាអាចរៀនបានល្អ និងមានការរីកចំរើនទៅមុខនៅក្នុងផ្នែកនេះ ។ ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះគ្រូបង្រៀនរបស់វាទាំងអស់ ដែលបានជំរុញលើកទឹកចិត្តគ្រប់ផ្នែកនៃជីវិតរស់នៅរបស់វា ហើយនិងបានជួយឲ្យយើងសង្ឃឹមទុកនូវកិរិតយល់ដឹងផ្នែកអាកប្បកិរិយាល្អរបស់វា ។

ខ្ញុំនៅចាំបានថា នៅពេលដែល*យ៉ូស្វេ*បានចូលរៀននៅឆ្នាំដំបូងនៅក្នុងទីក្រុងភ្នំពេញ គ្រូរបស់វាបានសួរថា "តើលោកស្រីបានធ្វើអ្វីដើម្បីជួយឲ្យ*យ៉ូស្វេ*ស្តាប់បង្គាប់?" អរគុណព្រះ នៅពេលនោះខ្ញុំបានដឹងថាមានរឿងមួយដែល*យ៉ូស្វេ*មិនចូលចិត្តបំផុតជាងអ្វីៗទាំងអស់នោះ គឺ "ផលវិបាក" ។ សូម្បីតែវានៅតូចនៅឡើយ វាយល់យ៉ាងច្បាស់ពីអត្ថន័យរបស់ពាក្យនោះ គឺថាជារឿងមួយដែលវាមិនចង់ជួបប្រទះឡើយ ។

"ផលវិបាកនោះ" គឺដូចជាការដែលវាត្រូវអង្គុយម្នាក់ឯងមួយស្របក់ មិនអនុញ្ញាតឲ្យទៅលេងជាមួយមិត្តភក្តិ ឬមិនឲ្យលេងជាមួយប្រដាប់លេងដែលវាពេញចិត្ត ខានបាននំផ្អែម ឬនំពេលញ៉ាំអាហាររួច ឬក៏មិនអនុញ្ញាតឲ្យមើលទូរទស្សន៍ជាដើម ។ រឿងសំខាន់ចំពោះផលវិបាកនោះ គឺជាការមួយដែលវាមិនចង់ទទួលរងទ្រាំ ។ ផលវិបាក ឬទណ្ឌកម្មខាងលើនោះ គឺមានន័យពិសេសណាស់ចំពោះ*យ៉ូស្វេ* ពីព្រោះវាជាក្មេងដែលចូលចិត្តនៅលេងជាមួយ

គេឯង លេងជាមួយមិត្តភក្តិ លេងជាមួយប្រដាប់លេងដែលវាស្រឡាញ់ ញ៉ាំស្ករគ្រាប់ និងមើលទូរទស្សន៍ ។

ផលវិបាកឬទណ្ឌកម្មដ៏មានប្រសិទ្ធិភាពនោះ មិនមែនគ្រាន់តែមិនចង់ទទួលប៉ុណ្ណោះទេ ប៉ុន្តែការនោះនឹងកើតឡើងភ្លាម បន្ទាប់ពីការដែលវាមានអាកប្បកិរិយាខុសមិនអាចទទួលយកបាននោះ ។ ឧទាហរណ៍ បើសិនយ៉ូស្វេប្រព្រឹត្តមិនត្រឹមត្រូវឥឡូវនេះ ការដាក់ពិន័យនោះត្រូវតែធ្វើភ្លាម ដើម្បីឲ្យវាអាចយល់ថា អ្វីដែលវាទទួលនៅពេលនេះ កើតមកពីអ្វីដែលវាបានប្រព្រឹត្តខុសនោះឯង ។

នៅពេលដែលខ្ញុំនិយាយថា "*យ៉ូស្វេ* តើកូនចង់ទទួលទណ្ឌកម្មឬទេ?" ខ្ញុំត្រូវតែមានអ្វីមួយនៅក្នុងគំនិតរបស់ខ្ញុំ ក្រែងការប្រព្រឹត្តិរបស់វាមិនបានប្រសើរឡើង ។ នៅពេលដែលខ្ញុំចាប់ផ្តើមប្រើវិធីនេះ ដំបូងខ្ញុំត្រូវតែបង្កើតការ "ដាក់ទណ្ឌកម្ម" មួយ ដើម្បីធ្វើការកែតម្រង់នោះ ។ ការនោះគឺវាហាក់បីដូចជា*យ៉ូស្វេ*កំពុងនិយាយនឹងខ្ញុំថា "ខ្ញុំពិតជាមិនជឿថា ម៉ាក់នឹងធ្វើអ្វីមួយដាក់ខ្ញុំនូវអ្វីដែលខ្ញុំមិនចូលចិត្តនោះឡើយ" ។ ឥឡូវនេះវាជឿខ្ញុំ ហើយកម្រហ៊ានល្បងលនឹងខ្ញុំទៀត នៅពេលដែលខ្ញុំសួរវានូវសំណួរអ្វីនោះ វាត្រូវតែឆ្លើយភ្លាម ។

ទោះជាយ៉ាងណាក៏ដោយវាមិនជាមនុស្សចចេសរឹងរូសឡើយ ។ យូរៗម្តងវាធ្វើដូចជាមេគោ ឈរស្ងៀមនៅមួយកន្លែង រឹងកំព្រឹសឥតកំរើកឡើយ ទោះបីជាមានគេខំព្យាយាមទាញយ៉ាងណាក៏ដោយ ។ តាមពិតទៅកាន់តែឆ្កឹសគោខ្លាំងប៉ុណ្ណា គោនោះកាន់តែរឹងទទឹងខ្លាំងប៉ុណ្ណោះដែរ! នៅក្នុងពេលបែបនោះ ការល្អប្រសើរសំរាប់*យ៉ូស្វេ*នោះ គឺត្រូវទុកវាឲ្យនៅតែម្នាក់ឯងរហូតដល់វាបានធូរស្រាលកំហឹងសិន ។

ទីបំផុតនេះ ខ្ញុំត្រូវតែព្យាយាមមិនប្រើជ្រុលពេកចំពោះវិធីនៃការ "ដាក់ទោស" ។ គឺមានន័យថា វាដូចជាក្រណាត់ វានឹងសឹកបើយើងប្រើវាញឹក

ញាប់ពេក វិធីកែតម្រង់អាកប្បកិរិយារបស់វាបែបនេះ នឹងមិនមានប្រយោជន៍តទៅទៀតទេ បើសិនខ្ញុំសួរសំណួរដដែលនោះញឹកញាប់ពេក ។

ជួនកាលខ្ញុំត្រូវគិតថា ហេតុអ្វីបានជាការប្រព្រឹត្តិរបស់*យ៉ូស្វេ*មិនបានសមរម្យសោះនៅពេលដែលខ្ញុំទុកឱកាសឲ្យវាកែ ។ នៅពេលថ្មីៗនេះគ្រូបង្រៀនរបស់វាបានទូរស័ព្ទហៅខ្ញុំពីសាលារៀននៅចំពេលបាយថ្ងៃត្រង់ ។ អ្នកគ្រូបាននិយាយថា៖ "*យ៉ូស្វេ* និងក្មេងប្រុសម្នាក់ទៀតកំពុងនៅក្នុងបន្ទប់ផ្លាស់សម្លៀកបំពាក់បន្ទាប់ពីគេហែលទឹករួច" "យើងបានឮយ៉ូស្វេស្រែកហើយរត់នៅខាងក្នុង ។ ពួកគេទាំងពីរបានវ៉ៃតប់គ្នា " ។ យើងមិនដឹងថាមូលហេតុអ្វីបាន*យ៉ូស្វេ*ខឹងខ្លាំងម្លេះជាមួយក្មេងប្រុសម្នាក់ទៀតនោះ ។ *យ៉ូស្វេ*គ្រាន់តែនិយាយថា "វាវ៉ៃខ្ញុំ" ។

បីបួនថ្ងៃក្រោយមក វេជ្ជបណ្ឌិតរបស់វាបានឮរឿងនេះ គាត់ក៏សួរថា "តើក្មេងប្រុសម្នាក់នោះជាសិស្សថ្មីឬ?"

ខ្ញុំឆ្លើយទាំងភ្ញាក់ថា "មែនហើយ ម៉េចបានជាអ្នកគ្រូពេទ្យដឹង?" "តាមពិតទៅក្មេងនោះជាសិស្សថ្មីមែន" តាមដែលអ្នកគ្រូនិយាយប្រាប់ខ្ញុំ ។

គ្រូបង្រៀនរបស់យ៉ូស្វេប្រាប់ខ្ញុំថា "នៅពេលដែលយ៉ូស្វេនិយាយអ្វីឬធ្វើអ្វីដល់ក្មេងដទៃទៀត នោះគេដឹងថាជាអំពើខិលដាក់គេ មិត្តសម្លាញ់ដែលស្គាល់វាច្បាស់គេនិយាយថា "កុំប្រកាន់វាអ្វី" ។ ពួកគេយល់យ៉ាងច្បាស់ពីអាយុដែលនៅវ័យក្មេងរបស់គេ ហើយគេយល់ថា ការអ្វីដែលគេធ្វើនោះគ្រាន់តែចង់ទាញចំណាប់អារម្មណ៍ពីគេតែប៉ុណ្ណោះ ដូច្នេះគេដឹងទើបគេធ្វើការសម្រេចចិត្តបានល្អប្រសើរគឺថា ធ្វើមិនដឹង ធ្វើមិនឮចំពោះ*យ៉ូស្វេ*!

នៅពេលដែលយ៉ូស្វេផ្ទុះកំហឹងឡើងភ្លាម ហើយមានអាកប្បកិរិយាមិនសមរម្យ ខ្ញុំបានសួរខ្លួនឯងថា "តើវាមានជម្ងឺអ្វីឬ? ខ្ញុំបានសង្កេតមើលពីការនេះគ្រប់គ្រាន់ល្មមដើម្បីរក្សាទុកចម្ងល់នេះនៅក្នុងគំនិតរបស់ខ្ញុំ ។ តាមពិតទៅ*យ៉ូស្វេ*ក៏មានសមត្ថភាពដើម្បីបញ្ចេញកំហឹងជាមួយក្មេងដទៃ ដូចជាក្មេងទាំង

ឡាយដែរ ។ យើងព្យាយាមស្វែងយល់ពីមូលហេតុដែលបណ្តាលឲ្យវាផ្ទុះកំហឹងឡើង ។ នៅក្នុងករណីកើតឡើងនៅក្នុងបន្ទប់ផ្លាស់សម្លៀកបំពាក់នោះខ្ញុំបានដឹងថា នៅប៉ុន្មានថ្ងៃក្រោយមក*យ៉ូស្វេ*មានបញ្ហាឈឺត្រចៀក ហើយតាមពិតទៅគឺ*យ៉ូស្វេ*ឈឺមែន ។ ប្រហែលបណ្តាលមកពីវាមានកំហឹងខឹងខ្លាំងនោះក៏មិនដឹង ។ ជួនកាលយើងក៏មិនអាចរកមូលហេតុឃើញដែរ ។



យើងមិនដឹងថា តើត្រូវចិញ្ចឹមបីបាច់រក្សាក្មេងនេះ...ឬក៏កូនរបស់យើងដទៃទៀតចំពោះបញ្ហានោះ ដោយរបៀបណាឡើយ។ យើងអធិស្ឋានសុំប្រាជ្ញាពីព្រះជាម្ចាស់ នោះព្រះអង្គនឹងព្រមឆ្លើយតាមសំណូមបែបនោះ ។[៦]

យើងមិនដឹងថា*យ៉ូស្វេ*មានសក្តានុពលខ្លាំងប៉ុណ្ណា តែព្រះជាម្ចាស់ជ្រាប ។ ព្រះអង្គជ្រាបពីផែនការរបស់ព្រះអង្គចំពោះកូនប្រុសរបស់យើង ។[៧] យើងមានសេចក្តីសង្ឃឹមយ៉ាងមាំ មិនមែនសំអាងលើអ្វីដែលគាត់អាចសម្រេចបាននៅក្នុងការមើលឃើញរបស់មនុស្សឡើយ ប៉ុន្តែដោយសារយើងជឿលើព្រះបន្ទូលរបស់ព្រះយេស៊ូដែលថា "គឺដើម្បីឲ្យការរបស់ព្រះបានសម្តែងមកក្នុងខ្លួនគាត់វិញ" ។[៨]

ឥឡូវនេះ ពេលដែលខ្ញុំគិតពីការដែលខ្ញុំទាស់ជាមួយព្រះជាម្ចាស់ចំពោះការទទួលកូនដូចជា *យ៉ូស្វេ*... ខ្ញុំបែរទៅជាញញឹមវិញ ។ គាត់ក្លាយទៅជាអំណោយទានដ៏មានតម្លៃដែលមិនបានគិតទុកជាមុន ។ "ឯព្រះ ផ្លូវនៃទ្រង់គ្រប់លក្ខណ៍[៩] ខ្ញុំសូមថ្វាយការសរសើរដល់ព្រះអង្គវិញ!

---

[៦] *យ៉ាកុប ១:៥*

[៧] *យេរេមា ២៩:១១*

[៨] *យ៉ូហាន ៩:៣*

[៩] *ទំនុក. ១៨:៣០*